**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៩ សរ

# សារាចរ

## ស្តីពី

## ការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ

ចាប់តាំងពីនីតិកាលទី១ នៃរដ្ឋសភា រហូតមកដល់បច្ចុប្បន្ននេះ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលបានជំរឿនមន្ត្រីរាជការស៊ីវិលចំនួន៣លើក រួចមកហើយ លើកទី១ នៅឆ្នាំ១៩៩៥ លើកទី២ នៅឆ្នាំ១៩៩៩-២០០១ និងលើកទី៣ នៅឆ្នាំ២០១០។ តាមរយៈលទ្ធផលនៃជំរឿនទាំងនេះ រាជរដ្ឋាភិបាលបានកសាងមូលដ្ឋានទិន្នន័យមន្ត្រីរាជការស៊ីវិលសម្រាប់ប្រើប្រាស់ក្នុងការពង្រឹង និងការគ្រប់គ្រងមន្ត្រីរាជការរហូតមកដល់បច្ចុប្បន្ន។

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់សមត្ថភាព ប្រសិទ្ធភាព និងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ តាមរយៈ (១) ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី (២)ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន និង(៣)ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ព្រមទាំងវិធានការគន្លឹះក្នុងការលើកកម្ពស់គុណភាពអប់រំ ដោយផ្តោតសំខាន់លើការពង្រឹងគុណភាពសាលារដ្ឋចាប់ពីថ្នាក់មត្តេយ្យសិក្សា ដល់មធ្យមសិក្សា។

ដើម្បីជំរុញបន្ថែមការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ និងវិធានការគន្លឹះក្នុងវិស័យអប់រំឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលសូមដាក់ចេញនូវការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ដូចខាងក្រោម៖

### ១. គោលបំណង

គោលបំណងនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ គឺដើម្បី៖

- កំណត់ឱ្យបានច្បាស់លាស់នូវរចនាសម្ព័ន្ធគ្រប់កម្រិតនិងគ្រប់ប្រភេទនៃគ្រឹះស្ថានសិក្សា។
- កំណត់ឱ្យបានច្បាស់លាស់នូវមន្ត្រីដែលបាននិងកំពុងបំពេញការងារជាក់ស្តែងនៅតាមគ្រឹះស្ថានសិក្សា។
- ធ្វើបច្ចុប្បន្នភាពនិងអភិវឌ្ឍប្រព័ន្ធទិន្នន័យតាមព័ត៌មានវិទ្យាគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ សម្រាប់ការគ្រប់គ្រងរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សា និងមន្ត្រីនៅតាមគ្រឹះស្ថានសិក្សា។
- កែលម្អឱ្យកាន់តែប្រសើរនូវប្រព័ន្ធបើកផ្តល់បៀវត្សដល់មន្ត្រីដែលកំពុងបំពេញការងារជាក់ស្តែងនៅតាមគ្រឹះស្ថានសិក្សា។



៩

## ២. ទិសាលភាព

ការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈនឹងត្រូវអនុវត្តសម្រាប់គ្រឹះស្ថានសិក្សា និងមន្ត្រីគោលដៅនៃគ្រឹះស្ថានសិក្សា ដូចខាងក្រោម៖

### ២.១ គ្រឹះស្ថានសិក្សាសាធារណៈគោលដៅ

- វិទ្យាល័យ
- អនុវិទ្យាល័យ
- សាលាបឋមសិក្សា
- សាលាមត្តេយ្យសិក្សា។

### ២.២ មន្ត្រីគោលដៅ

- មន្ត្រីរាជការក្របខ័ណ្ឌ
- មន្ត្រីជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីផ្សេងទៀតដែលបាននិងកំពុងបំពេញការងារដោយទទួលបៀវត្សឬប្រាក់ឧបត្ថម្ភពីថវិកាជាតិ ឬថវិកាអង្គភាព សម្រាប់រយៈពេលការងារចាប់ពី ៤(ប្រាំបួន)ខែ ឡើងទៅ។

## ៣. គោលការណ៍

ការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈត្រូវអនុវត្តផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- ពិនិត្យផ្ទៀងផ្ទាត់រចនាសម្ព័ន្ធជាក់ស្តែងរបស់គ្រឹះស្ថានសិក្សា ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- ពិនិត្យផ្ទៀងផ្ទាត់មន្ត្រីដែលបាននិងកំពុងបំពេញការងារជាក់ស្តែងនៅតាមគ្រឹះស្ថានសិក្សា ដោយប្រើប្រាស់ទិន្នន័យរបស់ក្រសួងមុខងារសាធារណៈជាមូលដ្ឋានគោល និងទិន្នន័យជាក់ស្តែងរបស់អង្គភាព។
- មិនអនុញ្ញាតឱ្យមានការផ្ទេរឬផ្លាស់ប្តូរអង្គភាពបំពេញការងាររបស់មន្ត្រីក្នុងអំឡុងពេលយុទ្ធនាការ។
- មិនអនុញ្ញាតឱ្យមានការកែតម្រូវឬកែប្រែទិន្នន័យឬព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពមន្ត្រីក្នុងអំឡុងពេលយុទ្ធនាការ។

## ៤. យន្តការនៃការដឹកនាំ គ្រប់គ្រង និងអនុវត្តយុទ្ធនាការ

យន្តការនៃការដឹកនាំ គ្រប់គ្រង និងអនុវត្តយុទ្ធនាការនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវរៀបចំនិងដាក់ឱ្យដំណើរការដូចខាងក្រោម៖

- គណៈកម្មការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវដឹកនាំនិងសម្របសម្រួលដោយក្រសួងមុខងារសាធារណៈ និងមានសមាសភាពចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត មន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរមុខងារសាធារណៈ (ដែលជាបន្តនឹងត្រូវបានហៅថា **គណៈកម្មការ**)។ សមាសភាពជាក់ស្តែងនៃគណៈកម្មការ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។



៥

- គណៈកម្មការ ត្រូវរៀបចំផែនការសកម្មភាពជាដំណាក់កាលនិងការចាប់ផ្តើមយុទ្ធនាការ, បែបបទនិងនីតិវិធី, វិធីសាស្ត្រ, សេចក្តីណែនាំ, ឯកសារនិងទម្រង់នានា, ប្រព័ន្ធព័ត៌មានវិទ្យា, ការផ្សព្វផ្សាយនិងការបណ្តុះបណ្តាល, ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ, ប្រព័ន្ធរបាយការណ៍និងមធ្យោបាយចាំបាច់នានា ដែលគាំទ្រដល់យុទ្ធនាការនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ។
- គណៈកម្មការ អាចរៀបចំបង្កើតអនុគណៈកម្មការ និងក្រុមការងារបច្ចេកទេសនានាតាមការចាំបាច់ ដើម្បីអនុវត្តនិងគាំទ្រដល់យុទ្ធនាការនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈឱ្យមានប្រសិទ្ធភាព និងឆ្លើយតបនឹងគោលបំណងដែលបានកំណត់។
- គណៈកម្មការ ត្រូវផ្តល់របាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលជាទៀងទាត់អំពីលទ្ធផលសម្រេចបានក្នុងដំណាក់កាលនីមួយៗនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ។

## ៥. ការចូលរួមនិងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

រដ្ឋបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដែលចូលរួមក្នុងយុទ្ធនាការនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវបំពេញភារកិច្ចនិងទទួលខុសត្រូវដូចខាងក្រោម៖

- ចាត់តាំងឱ្យមានក្រុមការងារទទួលបន្ទុកបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ដែលស្ថិតក្នុងភូមិសាស្ត្រនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយប្រើប្រាស់យន្តការការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាលេខាធិការដ្ឋាននៃក្រុមការងារ។ ក្រុមការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចូលរួមបំពេញការងារដែលជាតម្រូវការនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងស្របតាមការកំណត់របស់គណៈកម្មការ។
- ចូលរួមដោះស្រាយរាល់បញ្ហាប្រឈមនានាដែលអាចកើតមានក្នុងអំឡុងពេលយុទ្ធនាការ ដោយមានការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរមុខងារសាធារណៈ។
- ផ្តល់កិច្ចសហការនិងការគាំទ្រចាំបាច់នានាដល់គណៈកម្មការដើម្បីសម្រេចនូវគោលបំណងនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែង។
- ទទួលខុសត្រូវផ្ទាល់ចំពោះលទ្ធផលនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។

## ៦. ការចូលរួមនិងការទទួលខុសត្រូវរបស់មន្ត្រី

ក្នុងយុទ្ធនាការនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ថ្នាក់ដឹកនាំនិងមន្ត្រីដែលមានការពាក់ព័ន្ធត្រូវបំពេញភារកិច្ចនិងទទួលខុសត្រូវដូចខាងក្រោម៖

- ថ្នាក់ដឹកនាំនៃគ្រឹះស្ថានសិក្សាដែលមានកំណត់ក្នុងចំណុច **២.១** នៃសារាចរនេះ ត្រូវចូលរួមសហការនិងផ្តល់ការគាំទ្រឱ្យបានពេញលេញដល់យុទ្ធនាការនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែង ដែលបាននិងកំពុងបំពេញការងារនៅតាមគ្រឹះស្ថានសិក្សា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។



៩

- មន្ត្រីដែលមានកំណត់ក្នុងចំណុច **២.២** នៃសារាចរនេះ ត្រូវមានវត្តមានបំពេញការងារជាក់ស្តែងនៅតាមអង្គភាពរបស់មន្ត្រីសាមី។ មន្ត្រីដែលអវត្តមានឬបំពេញបេសកកម្មឬស្ថិតក្នុងស្ថានភាពផ្សេងទៀត ត្រូវមានឯកសារបញ្ជាក់ត្រឹមត្រូវនិងច្បាស់លាស់អនុលោមតាមលិខិតបទដ្ឋានជាធរមាន។ ក្នុងករណី មិនមានឯកសារបញ្ជាក់ត្រឹមត្រូវនិងច្បាស់លាស់ មន្ត្រីនោះនឹងត្រូវផ្អាកការបើកផ្តល់បៀវត្សជាបណ្តោះអាសន្ន និងត្រូវលុបឈ្មោះក្នុងរយៈពេល ១(មួយ)ខែក្រោយ ប្រសិនបើស្ថានភាពរបស់មន្ត្រីសាមីមិនត្រូវបានបញ្ជាក់ត្រឹមត្រូវនិងច្បាស់លាស់អនុលោមតាមលិខិតបទដ្ឋានជាធរមាន។
- ថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធក្នុងយុទ្ធនាការនៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តកំហុស ជាអាទិ៍ការក្លែងឬបន្លំឯកសារឬព័ត៌មាន នឹងត្រូវបណ្តេញចេញពីការងារ ដោយមិនគិតដល់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌផ្សេងទៀត។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៩រោច ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ